# គណៈកម្មការទន្លេមេគង្គតែងតាំងនាយកប្រតិបត្តិថ្មី

*ក្រុងវៀងច័ន្ទ ប្រទេសឡាវ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១*

លោក ហាន ហ្គូតមែន ត្រូវបានតែងតាំងជានាយកប្រតិបត្តិថ្មីនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ (MRCS) ។

លោក ហ្គូតមែន ដែលមានជំនាញខាងការគ្រប់គ្រង និងសម្របសម្រួលទីភ្នាក់ងារអភិវឌ្ឍន៍ចំនួន ៥០ នៅក្នុងប្រទេសខុសៗគ្នាទាំងប្រាំនៅតាមដងទន្លេមេគង្គ ក្នុងពេលដែលគាត់នៅធ្វើការឱ្យសម្ព័ន្ធភាពតំបន់ដីសើម (Wetlands Alliance) នឹងចូលកាន់តំណែងរបស់គាត់សម្រាប់រយៈពេលបីឆ្នាំ នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ក្នុងថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដែលនៅទីនោះលោកនឹងដឹកនាំក្រុមបុគ្គលិកជំនាញចំនួន ១៥០ រូប និងដឹកនាំការគ្រប់គ្រងការិយាល័យចំនួនពីរនៃលេខាធិការដ្ឋាននេះ ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ និងក្រុងវៀងច័ន្ទ។

ជំនាញបច្ចេកទេស និងចំណេះដឹងយ៉ាងច្រើនរបស់គាត់អំពីតំបន់នេះ ដែលបានមកតាមរយៈការរស់នៅក្នុងតំបន់នេះអស់រយៈពេលជិតពីរទសវត្សរ៍ នឹងអាចឱ្យគាត់ដឹកនាំគណៈកម្មការទន្លេមេគង្គ នៅក្នុងអំឡុងពេលនៃការកែប្រែ និងការរីកចម្រើននៅក្នុងគណៈកម្មការទន្លេមេគង្គ (MRC) ។

សញ្ជាតិស៊ុយអែដរបស់គាត់ មិនមែនជារឿងចម្លែកឡើយសម្រាប់គណៈកម្មការទន្លេមេគង្គ ឬចក្ខុវិស័យរបស់គណៈកម្មការនេះ ដោយសារគាត់បានធ្វើការក្នុងនាមជាប្រធានកម្មវិធីបរិស្ថានអស់រយៈពេលប្រាំមួយឆ្នាំ ពីឆ្នាំ ២០០១ ដល់ ២០០៧។

អតីតភាពរបស់គាត់នៅលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ អាចផ្ដល់ឱ្យគាត់នូវចំណេះដឹងសមស្របអំពីកិច្ចការសំខាន់ៗដែលប្រឈមចំពោះស្ថាប័ននេះ ដែលនឹងអាចឱ្យគាត់ដឹកនាំគណៈកម្មការនេះយ៉ាងមានប្រសិទ្ធភាពក្នុងអំឡុងពេលនៃការផ្លាស់ប្ដូរយ៉ាងសំខាន់មួយ នៅក្នុងតំបន់ដែលមានការប្រែប្រួលយ៉ាងឆាប់រហ័សនេះ។

លោក ហ្គូតមែន មានប្រសាសន៍ថា "ខ្ញុំមើលឃើញតំណែងនាយកប្រតិបត្តិ ថាជាឱកាសដើម្បីរួមចំណែកក្នុងការធ្វើឱ្យកិច្ចសហប្រតិបត្តិការរបស់គណៈកម្មការទន្លេមេគង្គទទួលជោគជ័យ និងមានចំណែកផ្ទាល់ខ្លួននៅក្នុងការធ្វើឱ្យមានភាពខុសគ្នានៅក្នុងគោលដៅដ៏មានសារៈសំខាន់ជាសកលនេះ ដើម្បីកែលម្អការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹកដ៏មានតម្លៃរបស់យើង" ។

ជាមួយឯកសារស្រាវជ្រាវជាច្រើនដែលគាត់បានរួមចំណែករៀបរៀងឡើងផងដែរនោះ គាត់បានការទទួលស្គាល់នៅទូទាំងតំបន់នេះ ថាជាអ្នកជំនាញនាំមុខមួយរូបលើការងារគ្រប់គ្រងធនធានវារីជាតិនៅក្នុងអាងទន្លេមេគង្គ។

បុរសដែលមានអាយុ ៤៦ ឆ្នាំ និងមានដើមកំណើតនៅហ្គោតេបឺក នៃប្រទេសស៊ុយអែដ មានកូនប្រុសម្នាក់ និងចូលចិត្តស្ទូចត្រីនៅពេលគាត់ទំនេរ។

**កំណត់សំគាល់សម្រាប់និពន្ធនាយក**

គណៈកម្មការទន្លេមេគង្គ (MRC) គឺជាទីភ្នាក់ងារអន្តររដ្ឋាភិបាលតែមួយគត់ ដែលធ្វើការដោយផ្ទាល់ជាមួយរដ្ឋាភិបាលនៃប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម ដែលទាក់ទងនឹងផលប្រយោជន៍ជាក់លាក់រួមរបស់ប្រទេសទាំងនេះ ពោលគឺ ការគ្រប់គ្រងធនធានទឹករួមគ្នា និងការអភិវឌ្ឍទន្លេមេគង្គដោយចីរភាព ។

ក្នុងនាមជាអង្គភាពសម្របសម្រួល និងផ្តល់យោបល់នៅថ្នាក់តំបន់មួយ គណៈកម្មការទន្លេមេគង្គមានគោលដៅដើម្បីធានាថា ទឹកទន្លេមេគង្គត្រូវបានអភិវឌ្ឍន៍តាមវិធីដែលមានប្រសិទ្ធភាពបំផុត និងដែលផ្តល់អត្ថប្រយោជន៍ឱ្យគ្នាទៅវិញទៅមក សម្រាប់ប្រទេសទាំងអស់ក្នុងអាងទន្លេមេគង្គ និងកាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់មកលើប្រជាជន និងបរិស្ថាននៅក្នុងអាងទន្លេមេគង្គក្រោម ។

តាមរយៈជំនាញបច្ចេកទេស និងទស្សនៈវិស័យនៅកម្រិតអាងទន្លេ គណៈកម្មការទន្លេមេគង្គផ្តល់សេវាដល់រដ្ឋជាសមាជិក និងដើរតួយ៉ាងសំខាន់នៅក្នុងការធ្វើសេចក្តីសម្រេចថ្នាក់តំបន់ និងការប្រតិបត្តិគោលនយោបាយតាមវិធីមួយ ដែលជម្រុញឱ្យមានការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ។

តាំងពីពេលបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩៥ នៅក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងទន្លេមេគង្គ គណៈកម្មការទន្លេមេគង្គបានអនុម័តបទបញ្ជា និងនីតិវិធីមួយចំនួន ដូចជា នីតិវិធីសម្រាប់គុណភាពទឹក ដើម្បីផ្តល់ជាដំណើរការជាលក្ខណៈប្រព័ន្ធ និងឯកភាពគ្នា សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ ។ គណៈកម្មការនេះ ក៏ដើរតួផងដែរជាមណ្ឌលចំណេះដឹងថ្នាក់តំបន់ អំពីកិច្ចការសំខាន់ៗមួយចំនួន ដូចជា ជលផល នាវាចរ ការគ្រប់គ្រងទឹកជំនន់និងគ្រោះរាំងស្ងួត ការតាមដានបរិស្ថាន និងការអភិវឌ្ឍថាមពលវារីអគ្គិសនី ។

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ គឺជាសេនាធិការប្រតិបត្តិមួយ ដែលមានបុគ្គលិកប្រមាណ ១៥០ នាក់ ធ្វើការនៅក្នុងការិយាល័យចំនួនពីរនៃលេខាធិការដ្ឋាន ដែលតាំងនៅក្នុងរាជធានីភ្នំពេញនៃប្រទេសកម្ពុជា និងក្រុងវៀងច័ន្ទនៃប្រទេសឡាវ ។ ស្ថាប័នបង្គោលនៃគណៈកម្មការនេះនៅក្នុងប្រទេសទាំងបួន ពោលគឺ គណៈកម្មាធិការជាតិទន្លេមេគង្គដែលជាអ្នកសម្របសម្រួលការងារនៅថ្នាក់ជាតិ ។

ទីភ្នាក់ងារនេះបើកឱកាសឱ្យអ្នកពាក់ព័ន្ធជាច្រើនចូលរួមនៅក្នុងការងារនានានៃកម្មវិធីរបស់ខ្លួន និងក្នុងការកសាងផែនការយុទ្ធសាស្ត្រ ។ រដ្ឋចំនួនពីរនៅខ្សែទឹកខាងលើនៃអាងទន្លេមេគង្គ ពោលគឺ សាធារណរដ្ឋប្រជាមានិតចិន និងសហភាពមីយ៉ាន់ម៉ា គឺជាដៃ-គូសន្ទនាជាមួយគណៈកម្មការទន្លេមេគង្គ ។

គណៈកម្មការទន្លេមេគង្គបានទទួលមូលនិធិគាំទ្រ ដែលជាវិភាគទានមកពីប្រទេសជាសមាជិកចំនួនបួន និងដៃគូអភិវឌ្ឍន៍ ពោលគឺ រដ្ឋាភិបាលនៃប្រទេសផ្សេងៗ ធនាគារអភិវឌ្ឍន៍ និងអង្គការអន្តរជាតិនានា ។

ចំពោះព័តិមានបន្ថែម សូមទាក់ទងមក :
លោក ស៊ូរ៉ាសាក់ ក្លាហាន - មន្ត្រីទំនាក់ទំនង
ទូរស័ព្ទ : +៨៥៦ ២៦៣ ២៦៣
+៨៥៦ ២០ ៥៥៥ ២៨៧២៦ (ទូរស័ព្ទចល័ត)
អ៊ីម៉ែល : Surasak@mrcmekong.org